# តើគេជឿអ្វីខ្លះ?

**ស្មរបន្ទាល់**ព្រះយេហូវ៉ាជឿទៅលើព្រះដែលមានគ្រប់ព្រះចេស្ដា គឺព្រះយេហូវ៉ាជាអ្នកដែលបង្កើតផ្ទៃមេឃនិងផែនដី។ អត្ថិភាពនៃរបស់អស្ចារ្យជាច្រើន ដែលបានគូរប្លង់មកយ៉ាងស្មុគស្មាញនៅក្នុងសកលលោក ដែលមានជុំវិញយើងសម្ដែងយ៉ាងសមហេតុសមផល ថាអ្នកបង្កើតដែលមានគ្រប់ព្រះចេស្ដា ហើយដែលមានបញ្ញាដ៏ឧត្ដមបំផុត បានបង្កើតរបស់សព្វសារពើទាំងនោះមែន។ ដូចកិច្ចការរបស់មនុស្សប្រុសនិងស្រីសម្ដែងគុណសម្បត្តិរបស់គេ គឺយ៉ាងដូច្នោះដែរ កិច្ចការរបស់ព្រះយេហូវ៉ាសម្ដែងគុណសម្បត្តិរបស់ទ្រង់។ ព្រះគម្ពីរថែងប្រាប់យើងថា:



Mountain High Maps®
Copyright ©1997 Digital Wisdom, Inc.

**ផែនដី ... បានបង្កើតដោយ**
**ព្រះយេហូវ៉ា ... ថែរក្សាដោយ**
**មនុស្សលោក ...ជាទីអាស្រ័យនៅជានិរន្តរ៍**

<<អ្វីៗរបស់ទ្រង់ដែលរកមើលមិនឃើញតាំងពីកំណើតលោកីយមក ទោះទាំងព្រះចេស្ដាដ៏នៅអស់កល្បជានិច្ច នឹងនិស្ស័យជាព្រះរបស់ទ្រង់ នោះឃើញច្បាស់វិញ ដោយពិចារណាយល់របស់ទាំងប៉ុន្មាន ដែលទ្រង់បានបង្កើតមក>>។ ថែមទៅទៀត ដោយគ្មានសំឡេងឬក៏ពាក្យសំដីអ្វីឡើយ នោះ<<ផ្ទៃមេឃសំដែងពីសិរីល្អនៃព្រះ>>។—រ៉ូម ១:២០; ទំនុកដំកើង ១៩:១—៤





មនុស្សមិនមែនសូនធ្វើឆ្នាំងពីដីឥដ្ឋ ឬធ្វើទូរទស្សន៍ និងកុំព្យូទ័រ ដោយគ្មានបំណងអ្វីឡើយ។ ផែនដីនិងរបស់ដែលបានបង្កើតនៅលើនោះ គឺរុក្ខជាតិហើយសត្វមានភាពអស្ចារ្យយ៉ាងក្រៃលែងជាងវត្ថុទាំងនោះទៅទៀត។ រូបកាយមនុស្សដែលមានកោសិកាច្រើនសែនកោដិ គឺពិតជាហួសពីសមត្ថភាពនៃការយល់របស់មនុស្សយើង សូម្បីតែខួរក្បាលដែលយើងប្រើដើម្បីគិតក៏អស្ចារ្យក្រៃលែងដល់ម្ល៉េះ ដែលយើងមិនអាចយល់ដែរ!

បើសិនជាមនុស្សលោកមានគោលបំណងក្នុងការបង្កើតដ៏តូចតាចរបស់គេដែលមិនសូវសំខាន់ នោះព្រះយេហូវ៉ាពិតជាមានគោលបំណងដែរចំពោះរបស់ដែលទ្រង់បានបង្កើតមកដែលមានភាពស្មុគស្មាញណាស់! សុភាសិត ១៦:៤បានសម្ដែងថាទ្រង់ពិតជាមានរាជបំណងមែន: <<ព្រះយេហូវ៉ាទ្រង់បានធ្វើគ្រប់របស់ទាំងអស់ឱ្យសមនឹងប្រយោជន៍របស់នោះឯង>>។



ព្រះយេហូវ៉ាបានបង្កើតផែនដីដើម្បីបំពេញគោលបំណងមួយ ដូចទ្រង់បានមានបន្ទូលទៅមនុស្សមួយគូដំបូងនោះថា: <<ចូរបង្កើតកូនឱ្យចំរើនជាច្រើនឡើង ឱ្យមានពេញពាសលើផែនដីចុះត្រូវបង្ក្រាបផែនដីហើយមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស នឹងជី វិតផងទាំងឡាយដែលកំរើកនៅផែនដី>> ។ (លោកុប្បត្តិ ១២:៨) ដោយព្រោះតែគេបានក្លាយទៅជាមនុស្សមិនស្តាប់បង្គាប់នោះ មនុស្សមួយគូនេះមិនបានបំពេញផែនដីដោយគ្រួសារដ៏សុចរិត ដែលនឹងថែរក្សាផែនដីនិងរុក្ខជាតិ និងសត្វដោយសេចក្តីស្រឡាញ់នោះទេ ។ ក៏ប៉ុន្តែការទទួលបរាជ័យរបស់គេនេះ មិនធ្វើឱ្យព្រះយេហូវ៉ាគ្មានជោគជ័យចំពោះគោលបំណងរបស់ទ្រង់ឡើយ ។ រាប់ពាន់ឆ្នាំក្រោយរឿងនេះបានត្រូវសរសេរមកថា: <<ព្រះយេហូវ៉ាដែលបានបង្កើត. . . ហើយប្រតិស្ឋានផែនដី ក៏តាំងឡើង មិនមែនបង្កើតមកឱ្យនៅទទេទេ >> ។ ទ្រង់ក៏ <<បានជបសូនបង្កើតឱ្យជាទីអាស្រ័យនៅ>> ។ ផែនដីនេះមិនត្រូវបំផ្លាញឡើយពីព្រោះ <<ផែនដីស្ថិតស្ថេរនៅជាដរាប>> ។ (អេសាយ ៤៥:១៨; សាស្តា ១:៤) គោលបំណងរបស់ព្រះយេហូវ៉ាចំពោះផែនដីនឹងត្រូវបានសម្រេចឡើង: <<គំនិតសំរេចរបស់អញនឹងស្ថិតស្ថេរនៅ អញនឹងធ្វើតាមបំណងចិត្តអញគ្រប់ប្រការ>> ។-អេសាយ ៤៦:១០

ហេតុដូច្នេះហើយ ស្មរបន្ទាល់ព្រះយេហូវ៉ាជឿថា ផែនដីនឹងស្ថិតស្ថេរនៅជារៀងរហូត ហើយថាមនុស្សទាំងអស់ទាំងមនុស្សនៅរស់និងមនុស្សស្លាប់ ដែលនឹងសុខចិត្តធ្វើស្របនឹងគោលបំណងរបស់ព្រះយេហូវ៉ាចំពោះផែនដីដែលនឹងត្រូវបានលាងស្អាតជាទីអាស្រ័យនៅ នោះអាចរស់នៅលើនោះជានិរន្តរ៍ ។ មនុស្សទាំងអស់បានទទួលភាពឥតគ្រប់ល័ក្ខណ៍ពីអ័ដាមនិងអេវ៉ាហើយដោយហេតុនេះគ្រប់គ្នាជាអ្នកមានបាប ។ (រ៉ូម ៥:១២) ព្រះគម្ពីរចែងប្រាប់យើងថា:<<ឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់>> ។ <<មនុស្សដែលរស់ គេដឹងថាខ្លួននឹងស្លាប់ជាមិនខាន តែមនុស្សស្លាប់ឥតដឹងអ្វីឡើយ>> ។ <<ឯព្រលឹងណាដែលធ្វើបាប គឺព្រលឹងនោះឯងនឹងត្រូវស្លាប់វិញ>> ។ (រ៉ូម ៦:២៣; សាស្តា ៩:៥; អេសេគាល ១៨:៤, ២០) បើអ៊ីចឹងមែន តើដោយរបៀបណាពួកគេអាចមានជីវិតរស់ឡើងវិញបាន ដើម្បីឱ្យមានចំណែកក្នុងពរទាំងប៉ុន្មាននៅលើផែនដីនេះ? ដោយសារតែវិធីមួយនេះឯង គឺយញ្ញបូជាតម្លៃលោះរបស់ព្រះយេស៊ូគ្រីស្ទ ដ្បិតទ្រង់មានបន្ទូលថា: <<ខ្ញុំជាសេចក្តីរស់ឡើងវិញ ហើយជាជីវិតអ្នកណាដែលជឿដល់ខ្ញុំទោះបើបានស្លាប់ហើយ គង់តែនឹងរស់ឡើងវិញដែរ>> ។ <<អស់ទាំងខ្មោចនៅក្នុងផ្នូរនឹងឮសំឡេងទ្រង់ ហើយនឹងចេញមក>> ។-យ៉ូហាន ៥:២៨, ២៩; ១១:២៥; ម៉ាថាយ ២០:២៨

តើរឿងទាំងនេះនឹងកើតមានឡើងតាមរបៀបណា? រឿងនេះបានត្រូវពន្យល់ក្នុង <<ដំណឹងល្អពីនគរ>> ដែលព្រះយេស៊ូបានចាប់ផ្តើមប្រកាសក្នុងកាលដែលទ្រង់គង់នៅផែនដីនេះ ។ (ម៉ាថាយ ៤:១៧–២៣) ប៉ុន្តែ សព្វថ្ងៃនេះស្មរបន្ទាល់ព្រះយេហូវ៉ាកំពុងផ្សព្វផ្សាយដំណឹងល្អនេះ ដោយវិធីយ៉ាងពិសេសណាស់ ។

# ជំនឿជាច្រើនរបស់ស្មរបន្ទាល់ព្រះយេហូវ៉ា

| ជំនឿ | មូលហេតុពីព្រះគម្ពីរ |
|---|---|
| ព្រះគម្ពីរជាបន្ទូលរបស់ព្រះហើយជាសេចក្ដីពិត | ធីម៉ូថេទី២ ៣:១៦, ១៧; ពេត្រុសទី២ ១:២០, ២១; យ៉ូហាន ១៧:១៧ |
| ព្រះគម្ពីរជាប្រភពដែលអាចពឹងទៅលើបានជាងប្រពៃណីទៅទៀត | ម៉ាថាយ ១៥:៣; កូល៉ុស ២:៨ |
| ព្រះនាមរបស់ព្រះគឺជាយេហូវ៉ា | ទំនុកដំកើង ៨៣:១៨; អេសាយ ២៦:៤ |
| ព្រះគ្រីស្ទជាព្រះរាជបុត្រនៃព្រះហើយជាអ្នកក្រោមបង្គាប់ទ្រង់ | ម៉ាថាយ ៣:១៧; យ៉ូហាន ៨:៤២; ១៤:២៨; ២០:១៧; កូរិនថូសទី១ ១១:៣; ១៥:២៨; |
| ព្រះគ្រីស្ទជាអ្នកដែលព្រះបានបង្កើតមុនគេបង្អស់ | កូល៉ុស ១:១៥; ម៉ាថាយ ១៥:៣; វិវរណៈ ៣:១៤; |
| ព្រះគ្រីស្ទបានសោយទិវង្គតដោយគេព្យួរនៅលើបង្គោលឈើមិនមែននៅ<br>លើឈើឆ្កាងទេ | កាឡាទី ៣:១៣; កិច្ចការ ៥:៣០ |
| ជីវិតខាងមនុស្សរបស់ព្រះគ្រីស្ទបានត្រូវចំណាយជាតម្លៃលោះសម្រាប់មនុស្សដែលស្តាប់បង្គាប់ | ម៉ាថាយ ២០:២៨; ធីម៉ូថេទី១ ២:៥, ៦; ពេត្រុសទី១ ២:២៤; |
| យញ្ញបូជាតែមួយគត់របស់ព្រះគ្រីស្ទជាការគ្រប់គ្រាន់ហើយ | រ៉ូម ៦:១០; ហេព្រើរ ៩:២៥–២៨ |
| ព្រះគ្រីស្ទបានត្រូវប្រោសពីសោយទិវង្គតជាបុគ្គលវិញ្ញាណដែលមានជីវិតអមតៈ | ពេត្រុសទី១ ៣:១៨; រ៉ូម ៦:៩; វិវរណៈ ១:១៧, ១៨ |
| វត្តមានរបស់ព្រះគ្រីស្ទត្រូវកើតឡើងតាមវិញ្ញាណ | ម៉ាថាយ ១៤:១៩; ម៉ាថាយ ២៤:៣; កូរិនថូសទី២ ៥:១៦; ទំនុកដំកើង ១១០:៧, ២ |
| ឥឡូវនេះយើងរស់នៅក្នុង <<គ្រាចុងបំផុត>> | ម៉ាថាយ ២៤:៣–១៤; ធីម៉ូថេទី២ ៣:១–៥; លូកា ១៧:២៦–៣០ |
| ព្រះរាជាណាចក្រនៅក្រោមព្រះគ្រីស្ទនឹងគ្រប់គ្រងទៅលើផែនដី ដោយសេចក្ដីសុចរិតហើយសន្តិភាព | អេសាយ ៩:៦, ៧; ១១:១–៥; ដានីយ៉ែល ៧:១៣, ១៤; ម៉ាថាយ ៦:១០ |
| ព្រះរាជាណាចក្រនាំមកស្ថានភាព | ទំនុកដំកើង ៧២:១–៤; វិវរណៈ ៧:៩, ១០; ១៣-១៧; |

| | |
|---|---|
| នៃជីវភាពដែលល្អបំផុតដល់ផែនដីយើងនេះ | ២១:៣, ៤ |
| ផែនដីនេះនឹងមិនដែលត្រូវបំផ្លាញចោល ឬក៏លែងមានមនុស្សអាស្រ័យនៅទាល់តែសោះ | សាស្ដា ១:៤; អេសាយ ៤៥:១៨; ទំនុកដំកើង ៧៨:៦៩ |
| ព្រះទ្រង់នឹងបំផ្លាញរបបសម័យនេះក្នុងសង្គ្រាមអើម៉ាគេដូន | វិវរណៈ ១៦:១៤, ១៦; សេផានា ៣:៨; ដានីយ៉ែល ២:៤៤; អេសាយ ៣៤:២; ៥៥:១០, ១១ |
| មនុស្សអាក្រក់នឹងត្រូវហិនវិនាសអស់កល្បជានិច្ច | ម៉ាថាយ ២៥:៤១-៤៦; ថែស្សាឡូនីចទី២ ១:៦-៩ |
| មនុស្សដែលព្រះសព្វព្រះហឫទ័យនឹងទទួល ជីវិតអស់កល្បជានិច្ច | យ៉ូហាន ៣:១៦; ១៧:៣; ម៉ាកុស ១០:២៩, ៣០ |
| មានផ្លូវតែមួយគត់ដែលនាំទៅឯជីវិត | ម៉ាថាយ ៧:១៣, ១៤; អេភេសូរ ៤:៤, ៥ |
| សេចក្ដីស្លាប់របស់មនុស្សជាលទ្ធផលពីអំពើបាបរបស់អដាម | រ៉ូម ៥:១២; ៦:២៣ |
| នៅពេលស្លាប់នោះព្រលឹងមនុស្សឈប់មានទាំងអស់ | អេសេគាល ១៨:៤; សាស្ដា ៩:១០; ទំនុកដំកើង ៦:៥; ១៤៦:៤; យ៉ូហាន ១១-១៤ |
| ស្ថានឃុំព្រលឹងមនុស្សស្លាប់[នរក]គឺជាផ្នូរទូទៅរបស់ មនុស្សលោក | យ៉ូប ១៤:១៣; វិវរណៈ ២០:១៣, ១៤ |
| សេចក្ដីសង្ឃឹមសម្រាប់មនុស្សស្លាប់គឺជាដំណើរស់ឡើងវិញ | កូរិនថូសទី១ ១៥:២០-២២; យ៉ូហាន ៥:២៨, ២៩; ១១:២៥, ២៦ |
| សេចក្ដីស្លាប់ដែលមកពីអ័ដាមនឹងត្រូវឈប់មាន | កូរិនថូសទី១ ១៥:២៦, ៥៤; វិវរណៈ ២១:៤; អេសាយ ២៥:៨ |
| មានតែហ្វូងតូចដែលមានចំនួន១៤៤.០០០នាក់ប៉ុណ្ណោះ ដែលទៅស្ថានសួគ៌ដើម្បីសោយរាជ្យ ជាមួយនឹងព្រះគ្រីស្ទ | លូកា ១២:៣២; វិវរណៈ ១៤:១, ៣; កូរិនថូសទី១ ១៥:៤០-៥៣; វិវរណៈ ៥:៩, ១០ |
| ពួក១៤៤.០០០ត្រូវកើត ជាថ្មីជាបុត្រាវិញ្ញាណរបស់ព្រះ | ពេត្រុសទី១ ១:២៣; យ៉ូហាន ៣:៣; វិវរណៈ ៧:៣, ៤ |
| កិច្ចសន្យាថ្មីបានត្រូវធ្វើជាមួយនឹង ជនជាតិអ៊ីស្រាអែលខាងវិញ្ញាណ | យេរេមា ៣១:៣១; ហេព្រើរ ៨:១០-១៣ |
| ក្រុមជំនុំរបស់ព្រះគ្រីស្ទត្រូវកសាងនៅលើអង្គទ្រង់ផ្ទាល់ | អេភេសូរ ២:២០; អេសាយ ២៨:១៦; ម៉ាថាយ ២១:៤២ |
| សេចក្ដីអធិស្ឋានត្រូវថ្វាយទៅតែ ព្រះយេហូវ៉ាមួយអង្គតាមរយៈព្រះគ្រីស្ទ | យ៉ូហាន ១៤:៦, ១៣, ១៤; ធីម៉ូថេ ២:៥ |

| | |
|---|---|
| មិនត្រូវប្រើបដិមាករអ្វីឡើយក្នុងការថ្វាយបង្គំ | និក្ខមនំ ២០:៤, ៥; លេវីវិន័យ ២៦:១; កូរិនថូសទី១ ១០:១៤; ទំនុកដំកើង ១១៥:៤-៨ |
| យើងត្រូវតែស្អប់នឹងជៀសវាងពីមន្តអាគម | ចោទិយកថា ១៨:១០-១២; កាឡាទី ៥:១៩-២១; លេវីវិន័យ ១៩:៣១ |
| អារក្សសាតាំងជាអ្នកគ្រប់គ្រងដែលមើលមិនឃើញរបស់លោកីយ៍នេះ | យ៉ូហានទី១ ៥:១៩; កូរិនថូសទី២ ៤:៤; យ៉ូហាន ១២:៣១ |
| គ្រីស្ទានម្នាក់មិនត្រូវមានចំណែកអ្វីឡើយជាមួយនឹងចលនាសាសនាខុសៗពីគ្នា | កូរិនថូស ៦:១៤-១៧; ១១:១៣-១៥; កាឡាទី ៥:៩; ចោទិយកថា ៧:១-៥ |
| គ្រីស្ទានម្នាក់ត្រូវញែកខ្លួនចេញពីលោកីយ៍ | យ៉ាកុប ៤:៤; យ៉ូហានទី១ ២:១៥; យ៉ូហាន ១៥:១៩; ១៧:១៦ |
| យើងត្រូវតែស្តាប់បង្គាប់ច្បាប់របស់មនុស្សដែលមិនប្រឆាំងនឹងច្បាប់របស់ព្រះ | ម៉ាថាយ ២២:២០, ២១; ពេត្រុសទី១ ២:១២; ៤:១៥ |
| បញ្ចូលឈាមទៅក្នុងរូបកាយ តាមមាត់ឬក៏តាមសរសៃឈាម ជាការប្រឆាំងនឹងច្បាប់របស់ព្រះ | លោកុប្បត្តិ ៩:៣, ៤; លេវីវិន័យ ១៧:១៤; កិច្ចការ ១៥:២៨, ២៩ |
| ត្រូវតែស្តាប់បង្គាប់ច្បាប់របស់ព្រះគម្ពីរខាងសីលធម៌ | កូរិនថូសទី១ ៦:៩, ១០; ហេព្រើរ ១៣:៤; ធីម៉ូថេទី១ ៣:២; សុភាសិត ៥:១-២៣ |
| ព្រះបានបញ្ជាឱ្យតែពួកអ៊ីស្រាអែលអនុវត្តតាមថ្ងៃឈប់សំរាកហើយបញ្ញត្តិនោះបានត្រូវបញ្ចប់ជាមួយនឹងក្រិត្យវិន័យរបស់លោកម៉ូសេ | ចោទិយកថា ៥:១៥; និក្ខមនំ ៣១:១៣; រ៉ូម ១០:៤; កាឡាទី ៤:៩, ១០; កូល៉ុស ២:១៦, ១៧ |
| ថ្នាក់បព្វជិតហើយឋានន្តរពិសេសជាការមិនត្រឹមត្រូវទេ | ម៉ាថាយ ២៣:៨-១២; ២០:២៥-២៧; យ៉ូប ៣២:២១, ២២ |
| មនុស្សលោកមិនមែនវិវត្តន៏ទេតែបានត្រូវបង្កើតវិញ | អេសាយ ៤៥:១២; លោកុប្បត្តិ ១:២៧; ម៉ាថាយ ១៩:៤ |
| ព្រះគ្រីស្ទបានសម្តែងគំរូដែលយើងត្រូវតែយកតម្រាប់តាមក្នុងការបំរើព្រះ | ពេត្រុសទី១ ២:២១; ហេព្រើរ ១០:៧; យ៉ូហាន ៤:៣៤; ៦:៣៨ |
| ពិធីបុណ្យជ្រមុជទឹកជានិមិត្តរូបចំពោះការឧទ្ទិសថ្វាយខ្លួន | ម៉ាកុស ១:៩, ១០; យ៉ូហាន ៣:២៣; កិច្ចការ ១៩:៤, ៥ម៉ាកុស ១:៩, ១០; យ៉ូហាន ៣:២៣; កិច្ចការ ១៩:៤, ៥ |
| ពួកគ្រីស្ទានប្រកាសប្រាប់ | រ៉ូម ១០:១០; ហេព្រើរ ១៣:១៥; អេសាយ ៤៣:១០- |

Copyright © 2004 Watchtower Bible and Tract Society of Pennsylvania. All rights reserved.